**សេចក្តីប្រកាសព័ត៌មាន**

## ស្ថានទូតអូស្ត្រាលី ភ្នំពេញ

**ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១៩**

# ឯកអគ្គរាជទូតអូស្ត្រាលី ចុះទស្សនកិច្ចក្នុងខេត្តមណ្ឌលគិរី និងរតនគិរី

ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា លោកជំទាវ Angela Corcoran នឹងចុះទស្សនកិច្ចក្នុងខេត្តមណ្ឌលគិរី និងរតនគិរី នៅថ្ងៃទី ២៤~២៦ ខែមិថុនា។ ឯកអគ្គរាជទូតអូស្ត្រាលី នឹងជួបជាមួយឯកឧត្តម ស្វាយ សំអ៊ាង អភិបាលខេត្តមណ្ឌលគិរី  និងឯកឧត្តម ថង សាវុន អភិបាលខេត្តរតនគិរី ព្រមទាំងអង្គការសង្គមស៊ីវិលមួយចំនួននៅក្នុងខេត្តរតនគិរី។

ឯកអគ្គរាជទូតអូស្ត្រាលី Angela Corcoran នឹងចុះទស្សនកិច្ចនៅតាមអង្គការនានា ដែលកំពុងអនុវត្តកម្មវិធីជំនួយអភិវឌ្ឍន៍អូស្ត្រាលីក្នុងខេត្តទាំងពីរនេះ។ នៅឯភាគឦសាននៃប្រទេសកម្ពុជា ប្រទេសអូស្ត្រាលី កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍ជនជាតិដើមភាគតិចក្នុងតំបន់ដាច់ស្រយាល ដើម្បីផ្តល់ការអប់រំពហុភាសា និងការអភិវឌ្ឍសហគមន៍ ព្រមទាំងកែលំអជីវភាពរស់នៅឲ្យកាន់តែប្រសើរ។

ឯកអគ្គរាជទូតអូស្ត្រាលី Angela Corcoran មានប្រសាសន៍ថា៖ «ការគាំទ្ររបស់អូស្ត្រាលី ក្នុងភាគឦសាននៃប្រទេសកម្ពុជា គឺដើម្បីធ្វើឲ្យជីវភាពរស់នៅរបស់ពលរដ្ឋកម្ពុជាមានភាពប្រសើរឡើង ដោយផ្តោតសំខាន់លើការធានាឱ្យមានការអភិវឌ្ឍប្រកបដោយបរិយាបន្ន ចំពោះសហគមន៍ជនជាតិដើមនៅក្នុងតំបន់»។

ជំនួយអូស្ត្រាលី ថែមទាំងបានចូលរួមលើកកម្ពស់សេវាសុខាភិបាល  និងការគាំពារសង្គមសម្រាប់ជនក្រីក្រ ការអភិវឌ្ឍកុមារតូច និងជួយដល់សហគមន៍ដែលពុំមានសេវាហិរញ្ញវត្ថុ នៅក្នុងខេត្តមណ្ឌលគិរី និងរតនគិរីផងដែរ។

ព័ត៌មានបន្ថែមអំពីជំនួយអភិវឌ្ឍន៍អូស្ត្រាលីនៅកម្ពុជា សូមចូលទៅកាន់៖

https://dfat.gov.au/geo/cambodia/development-assistance/Pages/development-assistance-in-cambodia.aspx

ព័ត៌មានផ្សេងៗ សូមទំនាក់ទំនងមកកាន់អ៊ីម៉ែល៖ Australian.Embassy.Cambodia@dfat.gov.au